អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងប្រណាំងវាយកូនបាល់ចូលកន្ត្រក**

**ចិត្តចលភាព**៖ បំណិនចលនាធំ៖ ការហ្វឹកហាត់បង្កើនកម្លាំងសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ

ការរីកចម្រើនរាងកាយនិងចលនា៖ ការបង្កើតកម្លាំង និងប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព

**បុរេគណិត**៖ បរិមាណនិងចំនួន៖ ស្គាល់និងយល់លេខតាង និងការគណនាសាមញ្ញ

**គោលបំណង** ៖

**ចិត្តចលភាព**៖ ប្រាប់បានពីរបៀបវិធីដើរ រត់ លូន លោត ចុះឡើង បោះ តោង ឡើង គប់ បង្វិល រមៀល រុញ និងទាញ ទៅតាមគោលដៅនិងចម្ងាយដែលបានកំណត់រួច។

អនុវត្តសកម្មភាពមួយបានយ៉ាងទន់ភ្លន់ រហ័សរហួននិងរឹងមាំដោយផ្តើមចេញពីចលនាមូលដ្ឋានងាយៗ ទៅលំបាក ចំនួនពីរឡើងទៅ ក្នុងនោះមានការដើរ រត់ លូន ឬលើសពីនេះតាមរយៈចលនាចរន្ត ហាត់ប្រាណតាមរឿងនិទាន បទចម្រៀង បទភ្លេងនិងល្បែងនានា។

**បុរេគណិត** ៖ ប្រាប់បានពីចំនួន លេខនិងយល់ន័យពីលេខ១ ដល់៣១ តាមលំដាប់លំដោយ ឬលើសពីនេះ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ប៉ោងប៉ោងមួយចំនួនល្មមនឹងសម្រាប់លេងល្បែងនេះ រ៉ាកែតវាយសី សម្រាប់វាយប៉ោងប៉ោងនិងកន្ត្រកមួយចំនួនតាមចំនួនក្រុម។ ប្រសិនបើអ្នកមិនច្បាស់ក្នុងការធ្វើរ៉ុកកែតទេ អ្នកអាចចូលមើលសន្លឹកណែនាំពីរបៀបធ្វើនៅក្នុងសកម្មភាព ល្បែងធ្វើរ៉ាកែតវាយសី បានផងដែរ។

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**ការរៀបចំ** ៖ ត្រៀមសម្ភារទាំងអស់សម្រាប់លេងល្បែងនេះជាមួយកុមារ។

**សេចក្តីណែនាំ**៖

1. ប្រាប់កុមារថាថ្ងៃនេះពួកគេនឹងលេងកីឡាមួយប្រភេទដែលមានឈ្មោះថា កីឡាវាយសី ដោយប្រើកូនបាល់ (បាល់ជ័រ ឬកៅស៊ូក៏បាន)។
2. សួរពួកគេថា ធ្លាប់បានលេងកីឡានេះពីមុនមកដែរឬទេ? លេងនៅទីណា? លេងជាមួយអ្នកណា?
3. ចាប់ផ្តើមបែងចែកកុមារជា២ក្រុម ឬបីក្រុមទៅតាមចំនួនសិស្សក្នុងថ្នាក់។
4. ត្រៀមរ៉ាកែត២ ឬ៣ ទៅតាមក្រុមដែលបានបែងចែក (ប្រសិនបើមាន៣ក្រុម រ៉ាកកែត៣ដែរ) កូនបាល់មួយចំនួននិងកន្ត្រក២ ឬ៣ តាមក្រុមដែលមានដូចគ្នា។
5. រៀបចំកន្លែងដាក់កន្ត្រក២ ឬ៣កន្លែង។ កន្ត្រក២សម្រាប់ដាក់កូនបាល់និង២ទៀតសម្រាប់វាយបញ្ចូល។

6. ក្មេងៗត្រូវនៅជាក្រុមដែលបានបែងចែករួច
7. ពន្យល់ក្មេងៗពីរបៀបលេងឱ្យបានច្បាស់ជាមុនសិន មុននឹងលេង
   ប្រសិនបើលេងជាក្រុម និងមានគ្នាច្រើនល្មម៖
   - យកក្មេងម្នាក់ពីក្រុមនីមួយៗ ដើម្បីចាប់ផ្តើមលេងល្បែងនេះ
   - ក្មេងៗក្នុងក្រុមនីមួយៗត្រូវប្រណាំងគ្នាវាយបាល់ឱ្យចូលក្នុងកន្ត្រកដែលបានរៀបចំដាក់នៅខាងមុខខ្លួនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
   - អ្នកគ្រូ ឬលោកគ្រូត្រូវកំណត់នាទីក្នុងការលេងម្តង អាចថា១ឬ២នាទីក៏បានដែរ ទៅតាមការកំណត់និងពេលវេលារបស់អ្នក។
   - ក្មេងក្នុងក្រុមនីមួយៗមានសិទ្ធិក្នុងការវាយកូបបាល់តែ១ដងទេ និងត្រូវប្តូរវេនទៅក្មេងក្នុងក្រុមបន្ទាប់ ហើយលេងបែបនេះរហូតដល់អស់នាទីដែលបានកំណត់ខាងលើ។
   - នៅពេលដែលគ្រប់នាទីដែលបានកំណត់នោះ អ្នកត្រូវស្រែកថា ‹‹ឈប់›› បន្ទាប់មករាប់ចំនួនកូនបាល់ដែលក្មេងបានវាយចូលនោះ។
   - ក្រុមណាដែលទទួលបាននកូនបាល់ច្រើនជាង ក្រុមនោះនឹងក្លាយក្រុមដែលឈ្នះតែម្តង
8. ប្រសិនបើអ្នកមានពេលវេលាគ្រប់គ្រាន់ សូមឱ្យក្មេងៗលេងបានគ្រប់គ្នាកាន់តែល្អ។
9. នៅពេលលេងល្បែងនេះរួចរាល់ហើយ អ្នកអាចចែកកូនបាល់ទៅឱ្យពួកគេក៏បានដែរ
   និងឱ្យពួកគេជួយរៀបចំកន្លែងលេងល្បែងឱ្យបានស្អាតនិងមានរបៀបរាបរយ។